# ទោះជាយ៉ាងណាក៏ត្រូវមានសោភ័ណភាព

ព្រាប ចាន់ម៉ារ៉ា
វិទ្យាស្ថានរៃយំ

មនុស្សលោកយើងនេះ ពុំថាសាសន៍ណា, សម្បុរអ្វី, ភេទអ្វី, រស់នៅទីណា...ឡើយ គឺសុទ្ធសឹងតែមានជាប់ជំពាក់ជាមួយសោភ័ណភាពជានិច្ច។ ឯសោភ័ណភាពនោះក៏ពុំអាចផ្ដាច់ចេញពីវប្បធម៌ផ្ទាល់នីមួយៗដែរ។ ដូច្នេះហើយ បានជាអ្វីៗដែលសង្គមមួយមើលឃើញថាល្អឬសង្ហាស្រស់ ជួនកាលក្រុមមនុស្សនៅឆ្ងាយគ្នាដែលមានវប្បធម៌ផ្សេងពីនោះ អាចមើលឃើញថាពុំគាប់ភ្នែកខ្លួនក៏មាន។ ខ្ញុំពុំមានបំណងយកចំណុចវប្បធម៌ខុសគ្នាមកពិភាក្សាឡើយ គ្រាន់តែចង់បញ្ជាក់ថា សោភ័ណភាព គេតែងយល់ថាជាការចាំបាច់។ ជាតិសាសន៍ដែលតូចតាចបំផុត ពុំនិយមយកសម្លៀកបំពាក់មកបិទបាំងខ្លួនឱ្យបានជិតយ៉ាងណា ក៏តែងមានគូរ, សាក់លើខ្លួន ឬពាក់គ្រឿងកំប៉ិកកំប៉ុកអ្វីផ្សេងៗ ដោយសារចង់ឱ្យមានសោភ័ណភាពដែរ។ លំនៅរាល់ថ្ងៃ ទោះជារយីករយាកយ៉ាងណាក៏ធ្វើឡើងតាមក្បួនខ្នាតជាមូលដ្ឋាន (ហៅថាស្ថាបត្យកម្ម) ជាពុំលែង បើពុំនោះនឹងរលំដួលចៀសពុំរួច។ ក្បួនខ្នាតសង់នោះសោត ក្រៅអំពីផ្នែកបច្ចេកទេសសុទ្ធសាធ ក៏តែងតែពាក់ព័ន្ធនឹងសោភ័ណភាពជានិច្ច។ និយាយមួយមាត់យ៉ាងខ្លីមក គឺអ្វីក៏ដោយមនុស្សតែងតែភ្ជាប់ទៅនឹងសោភ័ណភាព។ នេះជាចំណុចទីមួយ ឯចំណុចទីពីរ គឺយើងតែងសង្កេតឃើញថា កាលណាវត្ថុអ្វីមួយមានតួនាទីក្នុងសាសនា ឬជំនឿផ្សេងៗ គេកាន់តែយកចិត្តទុកដាក់ខ្លាំងឡើងថែមទៀតលើសោភ័ណភាព។ សំណង់តូចធំ ឬក៏វត្ថុនានាដែលពាក់ព័ន្ធរឿងនេះមិនអាចស្គាល់អស់ឡើយ ទោះជារាប់យកតែសំណង់ធំៗក៏ឃើញថាច្រើនឥតគណនានៅលើលោកនេះ។ ចំពោះប្រទេសកម្ពុជា ដូចយើងដឹងស្រាប់ហើយ លំនៅនៃទេពនានាដែលយើងហៅថា "ប្រាសាទ" នោះ ពីបុរាណកាលមកគឺមានធ្វើអំពីថ្មច្រើន ហើយមានមួយចំនួនសល់មកដល់យើងសព្វថ្ងៃ ទោះជាបាក់បែកតិចឬច្រើនក៏ដោយ។ ក្បូរក្បាច់រចនាលើថ្មប្រាសាទទាំងនោះមានការសិក្សាច្រើនណាស់មកហើយ ពុំចាំបាច់យកមកពោលនៅទីនេះទៀតទេ។ ចំណុចដែលខ្ញុំចង់បញ្ជាក់គឺនៅត្រង់គំនិតថា "ទេព" មិនចេះស្លាប់។ ដូច្នេះជាការធម្មតាទេ ដែលគេសង់ប្រាសាទជាថ្ម ព្រោះគេយល់ថាថ្មនៅគង់វង្សរហូតមិនអាចពុកផុយ។ អាស្រ័យហេតុនេះ សោភ័ណភាពដែលគេខំសម្រិតសម្រាំងឱ្យនៅជាមួយថ្ម ក៏គេ

ប្រាថ្នាឱ្យឆ្លងកាត់សម័យកាលដោយពុំមានការខូចខាតដែរ។ ក្រៅអំពីនោះ យើងគ្មានសល់អ្វីពីសម័យបុរាណមកពិចារណាឡើយ មានតែការបកស្រាយចម្លាក់ខ្លះៗដែលឃើញនៅជញ្ជាំងប្រាសាទ មានជាអាទិ៍ ប្រាសាទបាយ័ន្តនិងបន្ទាយឆ្មារ។

ដូច្នេះចូរយើងលោតមកសម័យបច្ចុប្បន្ន ដែលយើងអាចឃើញអ្វីៗផ្ទាល់ភ្នែក។ ការសាកល្បងត្រិះរិះរបស់ខ្ញុំនៅទីនេះ គឺផ្តោតតែទៅលើប្រការដែលមនុស្សខ្មែរយល់ថា "ទោះជាយ៉ាងណាក៏ត្រូវមានសោភ័ណភាព"។ ហេតុនេះហើយខ្ញុំនឹងយកតែឧទាហរណ៍វត្ថុអ្វីដែលមនុស្សធ្វើឡើងសម្រាប់ប្រើការតែមួយភ្លែត ឬមួយរយៈពេលខ្លីមកពិនិត្យ។

រូបលេខ១ គឺរូបអាស្រមមហាឫសី *(ស្រុកអង្គរបុរី, ខេត្តតាកែវ)* ដែលជាប្រាសាទថ្មមួយសាងនៅស.វ.ទី៦។ ដូចទើបនឹងពោលមកខាងលើនេះជាលំនៅទេព ម្ល៉ោះហើយយើងអាចយល់យ៉ាងងាយថា ហេតុអ្វីបានជាគេសង់មកពីថ្មហើយសម្អិតសម្អាងយ៉ាងខ្លាំងដូច្នេះ? ឥឡូវចូរយើងមើលរូបលេខ២ ដែលបង្ហាញពី "បន្ទប់ចាក" សាងឡើងសម្រាប់បុណ្យចាកមហាបង្សុកូល ដែលប្រព្រឹត្តិទៅតែមួយយប់បូកនឹងមួយព្រឹកឡើងទៀតប៉ុណ្ណោះ។ បើពោលតែកិច្ចដែលធ្វើនៅក្នុងបន្ទប់ និងច្រកផ្លូវកំណត់ដោយបង្គោលតូចៗនេះ សម្រាប់ព្រះសង្ឃនិមន្តចង្រ្កមភាវនា ឃើញថាមានរយៈពេលប្រមាណមួយម៉ោងប៉ុណ្ណោះ ហើយនៅពេលអធ្រាត្រទៀតផង។ បានជាគេរើសពេលដូច្នេះ ព្រោះការចាកដើម្បីចម្រើនអាយុមនុស្សនោះ ត្រូវធ្វើឡើងក្នុងភាពស្ងៀមស្ងាត់បំផុត ព្រមទាំងពុំមានពន្លឺទៀតផង ត្បិតមនុស្សចាស់ដែលគេចាកឱ្យនោះគេសន្មតថាចេញមកពីផ្ទៃម្តាយសាជាថ្មី។ ដូច្នេះតាមពិតទៅ នៅពេលសំខាន់បំផុតនោះ គ្មាននរណាពិនិត្យឃើញរូបរាងពិតប្រាកដ ព្រមទាំងពណ៌ផ្សេងៗនៃបន្ទប់ចាកនេះទេ។ បើគិតសើៗគេអាចនឹងយល់ថា ខំតុបតែងឱ្យអស់ពីចិត្ត តែពុំបានប្រយោជន៍អ្វីប្រាកដ ព្រោះគង់តែរើវីញមួយថ្ងៃក្រោយមក។ កំពូលដំបូលនេះ បើយកច័ត្ររួតចេញ គឺដូចគ្នានឹងកំពូលអាស្រមមហាឫសី ឬកំពូលប្រាសាទនៅភ្នំហាន់ជ័យ *(ប្រហែលសាងនៅស.វ.ទី៦ដែរ)* ទាំងស្រុង ត្បិតចម្លងតាមប្រពៃណីសិល្បៈឥណ្ឌា ដែលហៅកំពូលរាងដូចក្រពុំឈូកនោះថាជាផ្លែ "អាមលក"។ ឥឡូវចូរយើងមើលរូបលេខ៣ ដែលបង្ហាញពីការបូជាសពនៅក្រោមភ្នំយោងមួយ។ យើងឃើញថាភ្នំយោងដែលមានន័យដូចគ្នានឹងមេរុ *(ហៅតាមសំដីសៀមថា "មេន")* ដែរ ក៏មានផ្លែអាមលកទ្រច័ត្ររួតដូចគ្នា។ ភ្នំយោងនេះគ្មានខុសអ្វីពីរោងចាកអម្បាញ់មិញឡើយ ព្រោះសាងឡើងសម្រាប់តែមួយពេលបូជាប៉ុណ្ណោះ ហើយក៏រើចេញវិញ។ បើគិតពីការដែលរៀបចំ គឺចំណាយពេលវេលាច្រើនណាស់ហើយធ្វើឡើងក្នុងការព្យាយាមពេញទំហឹង ដូចរូបលេខ៤ *(ដំបូលទាំងមូល)* និងរូបលេខ៥ *(រូបលម្អិតពីអាមលក)* ជាតឹកតាងស្រាប់។ សំណង់សម្រាប់តែកិច្ចមួយភ្លែតដូច្នេះ ឃើញមាននៅក្នុងពិធីកោរជុកដែរ *(ពិធីនោះមានឫសគល់ពីព្រហ្មញ្ញសាសនានៅកម្ពុជាសម័យបុរាណមក)*។ ពិធីនេះក៏ប្រព្រឹត្តិទៅអស់រយៈពេលមួយយប់បូកនឹងមួយព្រឹកដូចបុណ្យចាកដូច្នោះ។ កិច្ចដែលធ្វើឡើងបន្តបន្ទាប់គ្នាមានច្រើនក្នុងវេលាយប់នោះ ហើយគេធ្វើនៅក្នុងផ្ទះ។ តែចំពោះកិច្ចកោរជុកជាបញ្ចប់ ហើយដែលប្រព្រឹត្តិទៅតែមួយភ្លែតសោះនោះ គឺត្រូវតែធ្វើឡើងនៅលើរោងមួយដែលមានន័យហាក់ដូចជាភ្នំកៃលាសដូច្នោះដែរ ហើយដែលគេហៅថា "រានម៉ា" ឬ "រានកោរ"។ ការសង់រាននេះ គ្រាន់តែមើលរូបលេខ៦ទៅក៏


រូបលេខ១


រូបលេខ២


រូបលេខ៣


រូបលេខ៤


រូបលេខ៥

យល់ហើយថាចំណាយធនធាន, ថាមពល និងតម្រូវឱ្យមានទេពកោសល្យច្រើនណាស់។ គេអាចសួរសំនួរដដែលថា ហេតុអ្វីក៏ផ្ចិតផ្ចង់ដល់ម្លេះ បើគ្រាន់តែធ្វើសម្រាប់មនុស្សឡើងកោរជុកពេលនោះក្នុងរយៈពេលប្រមាណ២០នាទីសោះ?

មិនតែប៉ុណ្ណោះទេ ជួនកាលគេយកពិធីអភិសេកព្រះមកភ្ជាប់នឹងការបូជាសពផង ដើម្បីបញ្ជូនកុសលផលបុណ្យនោះដល់សពដែលត្រូវទៅចាប់ជាតិថ្មី។ ពិធីដែលជាឧបសម្ព័ន្ធនេះក៏តម្រូវឱ្យមានការរៀបចំធ្វើ "គ្រែអាស្នា" ជាដើម ដើម្បីតម្កល់ព្រះដែលត្រូវអភិសេក។ ពិនិត្យតែរូបលេខ៧ទៅក៏ឃើញថា គ្រែនោះមានការតុបតែងសម្អិតសម្អាងខ្លាំងណាស់ ដោយប្រើការចាក់ចេកដូចទៅនឹងរានម៉ាលេខ៦ដែរ។ រានតូចតាចជាងនោះក៏មានចាក់ចេកដូចគ្នា ដូចមានឧទាហរណ៍នៅរូបលេខ៨។ រូបលេខ៩និង១០ បង្ហាញពីភាពលម្អិតនៃក្បាច់ព្រមទាំងការចាក់ចេកនោះ។

បើពោលពីភ្នំខ្សាច់វិញ គឺពុំត្រឹមតែធ្វើពេលចូលឆ្នាំនៅតាមវត្តឱ្យមនុស្សបានឃើញរាប់អាទិត្យប៉ុណ្ណោះឡើយ គឺគេអាចធ្វើដោយផ្ចិតផ្ចង់ដូចគ្នា តែសម្រាប់មួយរយៈពេលខ្លីក្នុងឱកាសបុណ្យច័ន្ទសុក្រគិរីសូត្រ ដែលជាបុណ្យចម្រើនអាយុឱ្យមនុស្សចាស់ដែរ។ ភ្នំខ្សាច់នោះជួនកាលឃើញមានពីរស្របគ្នា មួយគេពូននៅទីលានបុណ្យដូចជាភ្នំខ្សាច់នៅពេលចូលឆ្នាំដែរ (រូបលេខ១១) ក្នុងន័យថាពេលវេលាថ្មី (ត្បិតមនុស្សចាស់នោះកើតឡើងវិញសាជាថ្មី)។ ដូច្នេះហើយលោកក៏ត្រូវថ្មី ទើបបានជាធ្វើភ្នំខ្សាច់៥នោះក្នុងន័យជាសុខុមលោកដែលកើតឡើងវិញ។ ឯភ្នំខ្សាច់ទី២ គេពូនតម្កល់នៅលើរោងបុណ្យ ដោយមានភ្នំខ្សាច់ធំមួយនៅកណ្តាល និងតូចៗចំនួន១០០ទៀតនៅជុំវិញ (រូបលេខ១២) ដើម្បីឱ្យស្របនឹងពាក្យថា "អាយុយឺនយូរជាងរយព្រះវស្សា" ។ បើយោងពាក្យឱ្យពរថា "១០០ឆ្នាំ" គឺប្រហែលគេចាត់ទុកភ្នំកណ្តាលនោះដូចជាស្នូលនៃលោកនេះទៅវិញ។ លុះចប់បុណ្យនេះហើយ ភ្នំខ្សាច់ដែលចំណាយពេលវេលាយ៉ាងយូរដើម្បីធ្វើនេះក៏នឹងរលាយទៅវិញដោយចាប់បំផុត។

ឥឡូវចូរយើងក្រឡេកមើលប្រពៃណីទាក់ទងនឹងអារក្សម្តង។ នៅតំបន់អង្គរ មេមត់ម្នាក់ៗតែងមានជមពិសេសមួយដែលចាត់ទុកថាជា "គ្រូកំណើត" របស់ខ្លួន ហើយដែលតែងតែតម្កល់ទុកនៅលើហឹងតាមផ្ទះ។ មេមត់ម្នាក់ៗតែងបញ្ចេញយកមកសម្អិតសម្អាងសាជាថ្មី ដើម្បីកាន់រាំនៅពេលអារក្សចូលនៅតែក្នុងឱកាសឡើងរោងក្នុងមួយឆ្នាំម្តងប៉ុណ្ណោះ (រូបលេខ១៣)។ ក្បាច់ដែលចាក់លើស្លឹកត្នោតនោះមានច្រើនយ៉ាង ហើយមួយបែបៗសុទ្ធសឹងមានឈ្មោះពិសេស។ នៅទីនេះខ្ញុំសូមជូនឧទាហរណ៍ពីរ គឺរូបលេខ១៤និងលេខ១៥។ តាមធ្លាប់សង្កេតមើលមក ស្លឹកនេះតែងតែធ្លាក់សាជាថ្មីមួយឆ្នាំម្តង ដោយសារពុកខូច។ បើនៅតំបន់ខ្លះនៃខេត្តកំពង់ចាមវិញ មេមត់មានជមប្រចាំខ្លួនដូចគ្នាដែរហៅថា "ជមក្រញាញ់"។ ពេលឡើងរោងម្តងៗ គេធ្វើជមក្រញាញ់នេះពីរ ហើយដាក់ជិតគ្នាជារណ្តាប់។ មួយមានកំណាត់ដើមចេកជាទម្រ (រូបលេខ១៦) នៅចប់ពិធីឡើងរោងហើយ គេយកទៅចោលនៅឆ្ងាយពីផ្ទះបន្តិច (ដែលគេចាត់ទុកថាជាទីព្រៃ) ទោះជាខំធ្វើសម្អិតសម្អាងយ៉ាងណាក៏ដោយ។ ឯជមមួយទៀតមានផ្លែដូងជាទម្រ (រូបលេខ១៧) ដែលគេមិនចោលទេ គឺទុកនៅលើហឹងពេលពិធីចប់។ តែទោះជាយ៉ាងណាក៏ជមនេះត្រូវពុកខូច ហើយគេត្រូវតែធ្វើថ្មីពេលឡើងរោងក្រោយទៀត។



រូបលេខ៦



រូបលេខ៧



រូបលេខ៨



រូបលេខ៩



រូបលេខ១០



រូបលេខ១១



រូបលេខ១២


រូបលេខ១១៣

ក្រៅអំពីនេះ នរណាក៏ដឹងដែរថារណ្ដាប់ដូចជាបាយសី[១] ឬអ្វីទៀតជាដើម តែងតែធ្វើឡើងដោយផ្តិតផ្គង់ទោះជាត្រូវចោលភ្លាមក្រោយពីកិច្ចពិធីក៏ដោយ (រូបលេខ១១៨ និង១៩)។ សម្រាប់កិច្ចធ្វើធ្មេញក្នុងពិធីចូលវ័យនានា គេតែងបញ្ចុកទឹកដូងដល់អ្នកដែលគេធ្វើកិច្ចឱ្យនោះ។ រីដូងនោះគេពុំគ្រាន់តែកាប់ធម្មតាទេ គឺគេច្លាក់តួខ្លួនឱ្យមានក្បាច់ ហើយគេហៅថា "ដូងឡៅ" (រូបលេខ១២០)។ វត្ថុមួយទៀតដែលគួរឱ្យចាប់អារម្មណ៍ គឺផ្កាស្លានៅក្នុងមង្គលការ។ អាចារ្យវះយកផ្កានោះដោយមានរបៀប រួចទើបយកមកចងដោយផ្តិតផ្គង់តាមក្បួនច្បាប់នៃពិធី (រូបលេខ១២១ បង្ហាញពីផ្កាស្លាញី ឈ្មោល)។ មិនយូរប៉ុន្មានក៏ស្រាយឡើងវិញ ហើយបូតយកផ្កានោះចែកគ្នាដើម្បីបាចទៅលើគូស្វាមីភរិយានៅកិច្ចបញ្ចប់។ រូបលេខ១២២ បង្ហាញពីពិធីកោរជុកក្មេងស្រីម្នាក់។ ជុកដែលត្រូវកោរចេញនោះ គេមូរហើយស៊កទៅក្នុងវត្ថុធ្វើពីក្រមួនមួយ ហៅថា


រូបលេខ១១៤


រូបលេខ១១៥


រូបលេខ១១៦


រូបលេខ១១៧

[១] អ្នកស្រុកខ្លះនៅប្រើពាក្យដើមត្រឹមត្រូវ គឺ "បាយស្រី"។



"ពិន"។ ពិននោះប្រើតែមួយភ្លែតទេ ប៉ុន្តែរូបលេខ២២៣ បង្ហាញឱ្យឃើញច្បាស់ថា គេធ្វើដោយយកចិត្តទុកដាក់លើសោភ័ណភាពជាទីបំផុត ដោយគេយកគ្រាប់ស្រូវមកដោតតម្រៀបគ្នាជាជួរ ហើយជួរទាំងអស់នោះសុទ្ធសឹងផ្តេកបញ្ឈរសគ្នាគួរជាទីគាប់ភ្នែកក្រៃលែង។

រូបលេខ២១៨



រូបលេខ២១៩



រូបលេខ២២០



រូបលេខ២២១



រូបលេខ២២២



រូបលេខ២២៣

គិតមើលតែម្លួសក៏គួរពិចារណាដែរ គឺថាខំបិទក្រដាសពណ៌ដោយផ្ចិតផ្ចង់ ដើម្បីយកទៅដុតចោលប៉ុណ្ណោះ (រូបលេ២៤)។ ពែនាងគង្ហីងក៏មិនខុសអ្វីពីនោះដែរ គឺធ្វើឡើងដើម្បីកប់ចោលទៅក្នុងដីនៅពេលប្រុងពលី។ តែយ៉ាងណាក៏ធ្វើក្នុងភាពផ្ចិតផ្ចង់ដែរ (រូបលេខ២៥)។ នៅទីនេះគួរពិចារណារឿងគោមបន្ដិច។ ន័យដើមនៃការបង្ហោះគោម គឺមិនមែនសម្រាប់កម្សាន្តឬសប្បាយភ្នែកទាល់តែសោះ។ គេបង្ហោះគោមដើម្បីបញ្ជៀសឧបទ្រពឱ្យទៅឆ្ងាយ។ ដូច្នេះហើយបានជាគេជឿថា បើកាលណាគោមធ្លាក់នៅលើផ្ទះអ្នកណាមួយ គេត្រូវរកអាចារ្យធ្វើពិធីរម្ងាប់ហេតុការណ៍នោះ។ ម្យ៉ាងទៀតគេនិយាយថា នរណាឃើញគោមធ្លាក់មកនៅពេលអស់ប្រេងហើយ ត្រូវបន្ថែមប្រេង រួចបង្ហោះសាជាថ្មី ដើម្បីឱ្យគោមនោះទៅកាន់តែឆ្ងាយពីនោះទៅទៀត។ ពោលមកនេះគួរឱ្យយល់ហើយថា គោមភ្ជាប់នូវគ្រឿងមន្ទិលជាមួយខ្លួន។ តែមនុស្សមិនដែលផ្ដាច់សោភ័ណភាពពីការបង្ហោះនោះឡើយ គេតែងតែហ៊ោរកញ្ជៀវ មើលគោមនោះយ៉ាងសប្បាយភ្នែកខ្លាំងណាស់ ដោយសារសោភ័ណភាពនៃគោមដែលជះពន្លឺពីផ្ទៃមេឃពេលយប់នោះមានជាពិតប្រាកដ (រូបលេខ២៦និង២៧)។



រូបលេខ២៤

រូបលេខ២៥





រូបលេខ២៦

ខ្ញុំអាចយកឧទាហរណ៍សន្ទឹកសន្ទាប់មកបញ្ជាក់ទៀតក៏បាន ប៉ុន្តែខ្ញុំសូមបញ្ចប់ការត្រិះរិះលើសោភ័ណភាព ប្រភេទនេះដោយយកឧទាហរណ៍ម្ហូបអាហារមកបង្ហាញ។ នៅរូបលេខ១២៨ យើងឃើញមានអាហារពីរចាន មួយគឺខសាច់ជ្រូកជាមួយទំពាំង។ ទំពាំងដែលនឹងខាំទំពាចូលពោះបាត់នោះ ច្លាក់ជាក្បាច់ច្រើនបែបយ៉ាងដូចជារូបផ្កា, រូបស្លឹក, រូបត្រីជាដើម។ ក្នុងចានទីពីរគឺជាជ្រក់ល្ហុងនិងការ៉ុត។ សូមសង្កេតថា គេយកស្លឹកខ្ទឹមមកដោតនឹងល្ហុងព្រមទាំងការ៉ុតនោះ ឃើញហាក់ដូចជាទងផ្កា ត្បិតគេច្លាក់ការ៉ុតនិងល្ហុងមួយផ្នែកឱ្យមានរាងដូចផ្កាចម្ប៉ា។ រីឯគល់ខ្ទឹមគេច្រៀកឱ្យចេញជារាងផ្កាដែរ មើលទាំងអស់នោះទៅគួរឱ្យត្រេកាលក្អែក។ ធម្មតាការសម្អិតសម្អាងសោភ័ណភាពម្ហូបដល់កម្រិតនេះ យើងពុំប្រទះឃើញគ្រប់ពេលគ្រប់វេលាឡើយ។ ឯរូបដែលបង្ហាញនេះ គឺគេធ្វើដើម្បីជាចង្ហាន់សម្រាប់ប្រគេនព្រះសង្ឃ។ ចំណុចនេះគួរយកមកពិចារណា ត្បិតឧទាហរណ៍ទាំងអម្បាលម៉ានដែលឃើញពីលើមកសុទ្ធសឹងទាក់ទងនឹងជំនឿព្រមទាំងពិធីទាំងអស់។



រូបលេខ១២៧



រូបលេខ១២៨

ដូច្នេះប្រហែលយើងអាចពោលថា បើកម្រិតការបូជា ឬការគោរពកាន់តែខ្ពស់ កម្រិតនៃសោភ័ណភាពក៏កាន់តែខ្ពស់ដូចគ្នា។ តែទោះជាយ៉ាងណាក៏ដោយ នៅក្នុងជីវិតមនុស្សខ្មែរ អ្វីៗត្រូវតែមានសោភ័ណភាព។

កំណត់បន្ថែម

- រូបលេខ ៦, ២១, ២២ និង២៣ បានមកពីឯកសារនៃអតីត "នាយកដ្ឋានវប្បធម៌និងស្រាវជ្រាវ" (អាជ្ញាធរអប្សរា) ដែលចុះនៅតាមភូមិនានា ក្នុងក្របខ័ណ្ឌនៃកម្មវិធីស្រាវជ្រាវបេតិកភណ្ឌអរូបីនៅតំបន់អង្គរ។
- រូបលេខ ១១ និង១២ ជារបស់លោក ស៊ីយ៉ុន សុភារិទ្ធ។
- រូបលេខ ១៦ និង១៧ ជារបស់លោក ស៊ុន ចាន់ដឹប។